វិទ្យាស្ថានសភាកម្ពុជា
PARLIAMENTARY INSTITUTE OF CAMBODIA
STRENGTHENING PARLIAMENTARY CAPACITY

# ព្រឹត្តប័ត្រព័ត៌មានសង្ខេប

**សប្តាហ៍ដែលបញ្ចប់**
**ថ្ងៃទី២៤ ខែសីហា ២០១៨**

---

ចំណុចសំខាន់ៗ អំពីព័ត៌មានសេដ្ឋកិច្ច និងការអភិវឌ្ឍសារពើពន្ធនៅក្នុងបណ្តាប្រទេសជាសមាជិកអាស៊ាន និងនៅប្រទេសផ្សេងៗទៀត នៅក្នុងសប្តាហ៍នេះ គឺ៖

- កម្ពុជាប្រកាសពីគម្រោងធ្វើជំរឿនសម្រាប់ឆ្នាំ២០១៩
- សឹង្ហបុរី និងម៉ាឡេស៊ី រំពឹងថានឹងបន្តគម្រោង ការតភ្ជាប់ប្រព័ន្ធដឹកជញ្ជូនរហ័ស (RTS)
- លោកប្រធានាធិបតី ត្រាំ ត្រូវការ**ជំនួយពី**ធនាគារកណ្តាលទៅលើផ្នែកសេដ្ឋកិច្ច ដែលប៉ះពាល់ដល់ឯករាជ្យភាពរបស់ធនាគារកណ្តាល

*ព្រឹត្តប័ត្រសង្ខេបព័ត៌មាននេះ គឺជាព្រឹត្តិប័ត្រប្រចាំសប្តាហ៍ដែលរៀបចំឡើងដើម្បីតាមដានព័ត៌មានអំពីការអភិវឌ្ឍសេដ្ឋកិច្ច និងសារពើពន្ធថ្មីៗ នៅក្នុងប្រទេសកម្ពុជា និងដៃគូពាណិជ្ជកម្មនានា។ ឯកសារនេះត្រូវបានធ្វើឡើងដោយក្រុមការងារ បណ្តុះបណ្តាលសមត្ថភាពការវិភាគសារពើពន្ធរបស់វិទ្យាស្ថានសភាកម្ពុជា ក្នុងគោលបំណងពង្រឹងជំនាញនៃការធ្វើឯកសារ និងការស្រាវជ្រាវរបស់ខ្លួន។ ការងារនេះត្រូវបានព្យាយាមធ្វើឡើងដើម្បីធានាថាការវិភាគ និងអត្ថន័យ ដែលបានផ្តល់នៅក្នុងឯកសារនេះ មានគុណភាពខ្ពស់។ ទោះជាយ៉ាងណាក៏ដោយ សូមអ្នកអានចាត់ទុកឯកសារនេះជាផ្នែកមួយនៃលំហាត់អនុវត្តនៅក្នុងកំឡុងពេលនៃការបណ្តុះបណ្តាល។ យើងមិនអាចធានាថាឯកសារនេះល្អឥតខ្ចោះនោះទេ។*

## ព័ត៌មាន និងទិន្នន័យអំពីប្រទេសកម្ពុជា

### កម្ពុជាប្រកាសពីគម្រោងធ្វើជំរឿនសម្រាប់ឆ្នាំ២០១៩

មានប្រសាសន៍ទៅកាន់គណៈកម្មាធិការជាតិសម្រាប់ជំរឿនទូទៅឆ្នាំ២០១៩ ឯកឧត្តម ស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានអោយដឹងថា ក្រសួងផែនការនឹងចំណាយ១០លានដុល្លារអាមេរិច ពីថវិកាជាតិ ដើម្បីបំពេញការងាររបស់ខ្លួនទៅលើជំរឿនទូទៅឆ្នាំ២០១៩ ។

គម្រោងនេះនឹងបង្កើតការងារក្រៅម៉ោងចំនួន ៥០,០០០ ការងារ ។ រាជរដ្ឋាភិបាលបានជ្រើសរើសផ្តល់មូលនិធិផ្ទាល់របស់ខ្លួនទៅលើការងារនេះ ដោយមិនពឹងផ្អែកលើជំនួយបរទេស។

អ្នកប្រជាសាស្ត្ររំពឹងថា ចំនួនប្រជាជនកម្ពុជាអាចឈានដល់១៦លាននាក់ នៅក្នុងឆ្នាំ២០១៩។ ជំរឿននេះនឹងផ្តល់នូវព័ត៌មានដ៏សំខាន់សម្រាប់ការអភិវឌ្ឍរបស់កម្ពុជាដើម្បីឈានទៅសម្រេចបាននូវគោលដៅអភិវឌ្ឍប្រកបដោយនិរន្តភាព(២០១៦-២០៣០)។

### តារាងប្រចាំសប្តាហ៍៖ ឥណទានមិនដំណើរការនៅក្នុងធនាគារឯកជននៅកម្ពុជា

តារាងប្រចាំសប្តាហ៍នេះបង្ហាញពី ភាគរយនៃឥណទានមិនដំណើរការ ដែលមាននៅក្នុងធនាគារពាណិជ្ជ និងធនាគារឯកទេស នៅក្នុងឆ្នាំ២០១៦ និង២០១៧ ដោយយោងរបាយការណ៍របស់ធនាគារជាតិនៃកម្ពុជា។ ភាគរយនៃឥណទានមិនដំណើរការរបស់ធនាគារឯកទេសមានចំនួនខ្ពស់ជាងនៅធនាគារពាណិជ្ជ ទាំងក្នុងឆ្នាំ២០១៦ និងឆ្នាំ២០១៧ (បានន័យថា ឥណទានរបស់ធនាគារពាណិជ្ជមានសុវត្ថិភាពជាង និងមានការគ្រប់គ្រងល្អជាង)។ ទោះជាយ៉ាងណាក៏ដោយ ផលប័ត្រ (Portfolio) របស់ធនាគារឯកទេសមានការរីកចម្រើនគួរអោយកត់សម្គាល់ ដោយភាគរយនៃឥណទានមិនដំណើរការ មានការធ្លាក់ចុះ ០,៨ភាគរយពិន្ទុ នៅ

ឆ្នាំ២០១៧ ចំនែកឯ ឥណទានមិនដំណើរការនៅធនាគារពាណិជ្ជនៅរក្សាភាគរយដដែល។

**ឥណទានមិនដំណើរការ នៅក្នុងធនាគារឯកជននៅកម្ពុជា**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

# ព័ត៌មាន និងទិន្នន័យរបស់បណ្តាប្រទេសនៅក្នុងអាស៊ាន និងដៃគូពាណិជ្ជកម្មដទៃទៀត

## សិង្ហបុរី និងម៉ាឡេស៊ី រំពឹងថានឹងបន្តគម្រោង ការតភ្ជាប់ប្រព័ន្ធដឹកជញ្ជូនរហ័ស (RTS)

កិច្ចព្រមព្រៀងស្តីពីការតភ្ជាប់ប្រព័ន្ធដឹកជញ្ជូនរហ័សកំពុងត្រូវបានត្រួតពិនិត្យ បន្ទាប់ពីមានការផ្លាស់ប្តូររដ្ឋបាលនៅប្រទេសម៉ាឡេស៊ី។ ទោះបីជាយ៉ាងណាក៏ដោយ បន្ទាប់ពីកិច្ចពិភាក្សានៅក្នុងសប្តាហ៍នេះ រដ្ឋមន្ត្រីក្រសួងដឹកជញ្ជូនរបស់សិង្ហបុរី និងដៃគូរបស់ខ្លួនប្រទេសម៉ាឡេស៊ី បានបញ្ជាក់សារជាថ្មីអំពីការប្តេជ្ញាចិត្តទៅលើគម្រោងតភ្ជាប់ប្រព័ន្ធដឹកជញ្ជូនរហ័ស ពី Johor Bahru ទៅសិង្ហបុរី។ យោងតាមអ្នកនាំពាក្យរបស់ក្រសួងដឹកជញ្ជូន បានអោយដឹងថា "រដ្ឋមន្ត្រីទាំងពីរពឹងថានឹងពង្រឹងកិច្ចសហប្រតិបត្តិការដឹកជញ្ជូន និងដឹកនាំគម្រោងការតភ្ជាប់ប្រព័ន្ធដឹកជញ្ជូនរហ័សនេះដើម្បីអោយដំណើរការប្រព្រឹត្តទៅប្រកបដោយផ្លែផ្កា"។

គេសង្ឃឹមថា គម្រោងការតភ្ជាប់ប្រព័ន្ធដឹកជញ្ជូនរហ័ស នឹងបញ្ចប់ត្រឹមឆ្នាំ២០២៤ ហើយនឹងជម្រុញកំណើនសេដ្ឋកិច្ច និងជួយកាត់បន្ថយទៅលើការចំណាយលើការកកស្ទះចរាចរណ៍រវាងប្រទេសទាំងពីរ។

# សេដ្ឋកិច្ចសហរដ្ឋអាមេរិក និងទុនបម្រុងសហព័ន្ធ

## លោកប្រធានាធិបតី ត្រាំ ត្រូវការជំនួយពីធនាគារកណ្តាលទៅលើផ្នែកសេដ្ឋកិច្ច ដែលប៉ះពាល់ដល់ឯករាជ្យភាពរបស់ធនាគារកណ្តាល

នៅក្នុងសប្តាហ៍នេះ លោកប្រធានាធិបតីអាមេរិច ត្រាំ បានបង្ហាញនូវការអន់ចិត្តថា ការជ្រើសតាំងប្រធានធនាគារកណ្តាលរបស់គាត់ ធ្វើអោយអត្រាការប្រាក់មានការកើនឡើង និងបានសុំអោយមានដំនោះស្រាយ និងគោលនយោបាយរូបិយវត្ថុដែលមានលក្ខណៈធូររលុងជាងមុន។ រូបិយប័ណ្ណអាមេរិចបានធ្លាក់តម្លៃ ហើយមានក្តីបារម្ភថា ប្រធានាធិបតីអាចនឹងធ្វើអន្តរាគមន៍ ដើម្បីអោយអត្រាធ្លាក់ចុះ ឬពន្យារការកើនឡើងតាមគម្រោង ។

ជាធម្មតា ប្រធានាធិបតីអាមេរិចមិនលូកដៃនៅក្នុងគោលនយោបាយរូបិយវត្ថុទេ គឺប្រកាន់ខ្ជាប់នូវគោលការណ៍ឯករាជ្យភាពរបស់ធនាគារកណ្តាល។ អ្នកជំនាញផ្នែករូបិយវត្ថុ និងស្ថាប័នមើលឃើញថា ឯករាជ្យភាពរបស់ធនាគារកណ្តាលគឺជាគន្លឹះនៃស្ថេរភាពសេដ្ឋកិច្ច។

# ព័ត៌មានសម្រាប់សប្តាហ៍បន្ទាប់

ចំណងជើងសំខាន់ៗដែលនឹងត្រូវលើកឡើងនៅសប្តាហ៍បន្ទាប់រួមមាន៖ សេចក្តីសម្រេចចិត្តរបស់កូរ៉េខាងត្បូងទៅលើអត្រាការប្រាក់កាលពីថ្ងៃសុក្រ និងសមតុល្យនៃទិន្នន័យពាណិជ្ជកម្ម នៅក្នុងប្រទេសអាស៊ានមួយចំនួន រួមមានប៊្រុយណេ និងវៀតណាម។

ខាងក្រោមគឺជាប្រតិទិនពេញលេញនៃការចេញនូវទិន្នន័យ និងការអភិវឌ្ឍ ដែលក្រុម FACT នឹងចេញនូវសប្តាហ៍ក្រោយ៖

<u>ថ្ងៃច័ន្ទ ទី២៧ ខែសីហា ឆ្នាំ ២០១៨</u>

- សមតុល្យពាណិជ្ជកម្មរបស់ប្រទេសប៊្រុយណេ ខែឧសភា
- អតិផរណារបស់ប្រទេសប៊្រុយណេ ខែមិថុនា
- សមតុល្យពាណិជ្ជកម្មរបស់ហុងកុង ខែកក្កដា
- ប្រាក់ចំនេញផ្នែកឧស្សាហកម្មរបស់ចិន ខែកក្កដា

<u>ថ្ងៃអង្គារ ទី២៨ ខែសីហា ឆ្នាំ ២០១៨</u>

- ជំនឿទុកចិត្តរបស់អ្នកប្រើប្រាស់ (consumer confidence) របស់កូរ៉េខាងត្បូង ខែសីហា
- ផលិតកម្មផ្នែកឧស្សាហកម្មរបស់ថៃ ខែកក្កដា

ថ្ងៃពុធ ទី២៩ ខែសីហា ឆ្នាំ ២០១៨

- សមតុល្យពាណិជ្ជកម្មរបស់វៀតណាម ខែសីហា
- អតិផរណារបស់វៀតណាម ខែសីហា
- សមតុល្យពាណិជ្ជកម្មរបស់ប្រ៊ុយណេ ខែមិថុនា
- ជំនឿទុកចិត្តរបស់អ្នកប្រើប្រាស់ (consumer confidence) នៅជប៉ុន ខែសីហា

ថ្ងៃព្រហស្បត្តិ៍ ទី៣០ ខែសីហា ឆ្នាំ ២០១៨

- ជំនឿទុកចិត្តរបស់ធុរៈកិច្ច (business confidence) របស់កូរ៉េខាងត្បូង ខែសីហា
- សន្ទស្សន៍តម្លៃអ្នកផលិត (Producers′ Price Index) ខែសីហា
- ការលក់រាយរបស់ជប៉ុន ខែកក្កដា

ថ្ងៃសុក្រ ទី៣១ ខែសីហា ឆ្នាំ ២០១៨

- ទិន្នផលផ្នែកសាងសង់របស់កូរ៉េខាងត្បូង ខែកក្កដា
- ការលក់រាយរបស់កូរ៉េខាងត្បូង ខែកក្កដា
- អតិផរណារបស់ជប៉ុន ខែសីហា
- អត្រាអត់ការងារធ្វើរបស់ជប៉ុន ខែកក្កដា
- ផលិតកម្មឧស្សាហកម្មរបស់ជប៉ុន ខែកក្កដា
- ការសម្រេចទៅលើអត្រាការប្រាក់របស់កូរ៉េខាងត្បូង
- ការលក់រាយរបស់ថៃ ខែមិថុនា ៕

*************************